ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសប្បុរសជន និងក្រុមការងារ ចំនួន១៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច និងបានឧបត្ថម្ភថវិកាជួយកសាងវិហារឥស្លាមអាល់អាហ្ស៊ីម នៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

១-លោក សេន សុះ

២-លោក សាន់ សារ៉ែន

៣-លោក គ្រេស ម៉ាន់ស៊ូរ

៤-លោក យោប អះស្គារី

៥-លោក សេត មូហាំម៉ាត់ហ្វ៊ីស

៦-លោក សាន់ សារី

៧-លោក សេន ហ្វារីត

៨-អ្នកស្រី ម៉ាន ចិន្តា

៩-អ្នកស្រី តាំ សារ៉ស់

១០-លោក ម៉ាត់ ខលៀ

១១-លោក ដេត ស៊ុបព្រី

១២-លោក ភូប មីន
១៣-លោក យ៉ុប សាឡេះ
១៤-លោក ម៉ាត់ ឡោះ
១៥-លោក ស្មាន យូ
១៦-លោក ហ៊ីម ខល្មៀ
១៧-លោក ស៊ុះ លី
១៨-លោក ឡិប យូស៊ុះ
១៩-លោក មូសា ពិន យ៉ាកភូប

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៦ . អនក្រ . តស

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូនសប្បុរសជន និងក្រុមការងារ ចំនួន០៨រូប ដែលមានស្នាដៃល្អប្រសើរក្នុងការបំពេញភារកិច្ច និងបានឧបត្ថម្ភថវិកាចូលរួមកសាងវិហារឥស្លាមអាល់អាហ្ស៊ីម នៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម **ទូនី រ៉សេត**
២-ឯកឧត្តម **ស្មាន ម៉ាណាន**
៣-ឯកឧត្តម **សាន់ សាប់អី**
៤-លោក **ម៉ូហាំម៉ាត់ អាប់ឌុលឡោះ**
៥-លោក **ហ៊្សុលមី ពិន មូហាំម៉ាត់**
៦-លោក **សាន់ ឡាតិន**
៧-លោក **អ៊ីម៉ាន ពិន យូសុះ**
៨-លោក **ម៉ន គ្រីយ៉ា**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០១ អនក.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ជនជាតិម៉ាឡេស៊ី ចំនួន០៦រូប ដែលបានឧបត្ថម្ភថវិកាជួយកសាងវិហារឥស្លាមអាល់អាហ្ស៊ីម នៅភូមិព្រែកតាពៅ សង្កាត់ដើមមៀនក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

១- HAJI AMI NARDIN HAJI ISHAK

២- USTAZ AZHAR BIN DATO` ABDUL SHUKUR

៣- USTAZ SHAMSHURI BIN HAJI ASHAARI

៤- PUAN SRI HAMIDAH ABDUL RAHMAN

៥- DATIN SITTI RAHMAH JAJI ABDUL HAMID

៦- EKMAL HAMID ZAKARIA

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៥១៧...អនក្រ.តស

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ ជូនថ្នាក់ដឹកនាំខេត្តសុកទ្រាំង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០៣រូប ដែលមានគុណបំណាច់និងស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ ដោយបានជួយឧបត្ថម្ភថវិកាកសាងអគារតំបន់ប្រតិបត្តិការសឹករងកែបកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម ឡេ ថាញ់កន់ (LE THANH CON) អនុលេខាគណៈកម្មាធិការបក្សខេត្តសុកទ្រាំង
២-ឯកឧត្តម ជីន ថាញ់ងៀម (TRAN THANH NGUYEN) អនុប្រធានគណៈកម្មាធិការប្រជាជន ខេត្តសុកទ្រាំង
៣-វរសេនីយ៍ឯកឡេ ជុងហ៊ូវ (LE TRUNG HUU) ប្រធាននយោបាយយោធា ខេត្តសុកទ្រាំង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៥១៣..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ខៀម ខេមរា** អត្តលេខ ៥៧៨៤៣

២- លោកវរសេនីយ៍ទោ **ជា ឫទ្ធី** អត្តលេខ ៥៥៩៧២

៣- លោកវរសេនីយ៍ទោ **ឯម សុខឿន** អត្តលេខ ៥៤៥១៩

៤- លោកស្រីវរសេនីយ៍ទោ **មុំ សាយន** អត្តលេខ ០៥០១៧ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ** ចំនួន ០៦គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ជួយកសាង ព្រះវិហារ នៅវត្តសិរីវ័ន ហៅវត្តព្រៃកំពែង ស្ថិតនៅក្នុងឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម៖

១- អ្នកស្រី **គីម ឈាន**

២- លោក **នៅ អួន**

៣- លោក **ឃុន ស្រេង**

៤- លោក **ខៀវ ឈន់**

៥- លោក **ទ៉ាន់ ម៉ិនថាន**

៦- លោក **ចេង លី**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧១.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ចំនួន ០៥គ្រឿង ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការ ជួយកសាងព្រះវិហារ នៅវត្តសិរីវ័ន ហៅវត្តព្រែកពែង ស្ថិតនៅក្នុងឃុំអញ្ជើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម៖

១- លោក អ៊ិន សុផល
២- លោក សន ទ្រី
៣- លោក លឹម ឃាន
៤- លោក ប៉ែន សុផាត
៥- លោក យ៉េម ចន

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៦.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ១៧គ្រឿង ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ជួយកសាង ព្រះវិហារ នៅវត្តសិរីវ័ន ហៅវត្តព្រៃកំពែង ស្ថិតនៅក្នុងឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមាននាមព្រះនាម និងនាមខាងក្រោម៖

១-	ព្រះតេជគុណ	សឿន សុខ	១០-	លោក	ជួន សុឃឿន
២-	លោក	សាយ ហុំ	១១-	លោក	អេង ឡាយ
៣-	លោក	ម៉ៅ សារុំ	១២-	លោក	ភាន់ សារាម
៤-	លោក	អ៊ឹម យ៉ឹន	១៣-	លោកយាយ	ឆឹម
៥-	លោក	គិន ព្រឿល	១៤-	លោក	ប៊ុន ហៃ
៦-	លោក	ម៉ាន់ អ៊ាន	១៥-	អ្នកស្រី	យ៉ាត ចន្ថា
៧-	លោក	សុខ សុផា	១៦-	លោក	ម៉ែន បូរ៉ាន់
៨-	លោក	គង់ ផល្លា	១៧-	លោក	សាំង ហុង
៩-	លោក	ម៉ាន់ ចាន់រិត			

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ខួន សំអាត** ជាទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើអគ្គនាយករង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ថុល ចាន់ថន** ជាជំនួយការលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ស៊ិន សុខន** អត្តលេខ ១៥១២៨
២- លោកវរសេនីយ៍ទោ **មិន ធុន្នី** អត្តលេខ ០១១៣២
៣- លោកវរសេនីយ៍ទោ **យឹម ប៊ិនហោ** អត្តលេខ ០៤៩៨២
៤- លោកវរសេនីយ៍ទោ **សុខ ទ្រី** អត្តលេខ ០១១២៩
៥- លោកវរសេនីយ៍ទោ **ឈឹម ដារ៉ា** អត្តលេខ ០២១៣០
៦- លោកវរសេនីយ៍ទោ **ហ៊ី សុមេធ** អត្តលេខ ០៥៣៣០ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **រស់ សុខផល្លណា** អត្តលេខ ៥៦២៤៣

២- លោកវរសេនីយ៍ទោ **ញៀម ម៉ុន្តរិទ្ធ** អត្តលេខ ០៥១៥០ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ស្វាយ សោភិន** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានកាសែតកម្ពុជា អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP ជំនួសលោក **នុត ឈឿង** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៨.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា ចំនួន០១គ្រឿង ជូនលោកវេជ្ជបណ្ឌិត អ៊ឹម សុនាត ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិខាងលិច ដែលមានស្នាដៃល្អចូលរួមចំណែកក្នុងការសាងសង់អគារមណ្ឌលសុខភាព គោករការ ចំនួនមួយខ្នង និងបំពាក់សម្ភារៈបរិក្ខារ ស្ថិតនៅរាជធានីភ្នំពេញ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ចំនួន០១គ្រឿង ជូនលោក ប៉ាទ្រីគ ស៊ីហ្គ័រ (Mr.PATRIEK SEGER) ប្រធានអង្គការ Samaritan Purse International ប្រចាំនៅកម្ពុជា ដែលបានខិតខំទំនាក់ទំនងទាញយកប្រភពថវិកាក្នុងការសាងសង់អគារមណ្ឌលសុខភាពគោករការ ចំនួនមួយខ្នង និងបំពាក់សម្ភារៈបរិក្ខារ ស្ថិតនៅរាជធានីភ្នំពេញ សរុបថវិកា ចំនួន ៦២.៦៦៨ ដុល្លារអាមេរិក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង និងពលទាហាន ចំនួន១១៩រូប ចំណុះយោធភូមិភាគទី៤ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-	វរសេនីយ៍ឯក	**ឈន**	**ធី**	០០៩៩៥៩	នាយការិយាល័យទី៤ យោធភូមិភាគទី៤
២-	វរសេនីយ៍ទោ	**ឆាន់**	**ចណ្ណា**	១៤៤២១៤	នាយរងលេខាធិការដ្ឋាន យោធភូមិភាគទី៤
៣-	វរសេនីយ៍ទោ	**ម៉េខជ**	**ឌីម៉ង់**	០៨៨៥៥៨	នាយរងការិយាល័យទី៣ យោធភូមិភាគទី៤
៤-	វរសេនីយ៍ទោ	**ស៊ិន**	**ឃឿម**	០០៩៩៧៦	នាយករងមន្ទីរពេទ្យ យោធភូមិភាគទី៤
៥-	វរសេនីយ៍ទោ	**សូ**	**សាម៉េន**	០១៨៩៧៩	នាយករងមន្ទីរពេទ្យ យោធភូមិភាគទី៤
៦-	វរសេនីយ៍ទោ	**ឈឿន**	**ប៊ុនលី**	០០៩៩៧៧	នាយករងមន្ទីរពេទ្យ យោធភូមិភាគទី៤
៧-	វរសេនីយ៍ទោ	**តឿ**	**ថន**	០១៩០៥៤	នាយករងតំបន់អភិវឌ្ឍន៍ យោធភូមិភាគទី៤
៨-	វរសេនីយ៍ទោ	**គ្រួច**	**សេម**	០០៩៩៨១	នាយរងការិយាល័យទី៤ យោធភូមិភាគទី៤

៩-	វរសេនីយ៍ទោ	ទិន	ម៉ីនហេង	០០៤១៩៣	នាយរងការិយាល័យទី៤ យោធភូមិភាគទី៤
១០-	វរសេនីយ៍ទោ	នុត	គីមឈិន	០១៩០០៨	នាយរងការិយាល័យទី៤ យោធភូមិភាគទី៤
១១-	វរសេនីយ៍ទោ	អ៊ុង	សុវណ្ណ	០១៩០០៣	នាយរងការិយាល័យទី៤ យោធភូមិភាគទី៤
១២-	វរសេនីយ៍ទោ	យ៉ាន់	ស្រស់	០២៩៤៨៨	មេបញ្ជាការ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១៣-	វរសេនីយ៍ត្រី	ពេជ្រ	សាលី	០២៩៤៧០	ជំនួយការការិយាល័យព្រំដែន យោធភូមិភាគទី៤
១៤-	វរសេនីយ៍ត្រី	សារិន	រដ្ឋាឧត្តម	០៧២២៧៩	ជំនួយការការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី៤
១៥-	វរសេនីយ៍ត្រី	មីន	ឈួរ	០១៩០១៦	នាយរងការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី៤
១៦-	វរសេនីយ៍ត្រី	ដួង	ចណ្ណា	០៥០៣៥៤	នាយរងការិយាល័យទី៤ យោធភូមិភាគទី៤
១៧-	វរសេនីយ៍ត្រី	អ៊ុង	ផេង	០៥០៥៦១	ជំនួយការស្បៀងការិយាល័យទី៤ យោធភូមិភាគទី៤
១៨-	វរសេនីយ៍ត្រី	ផាត់	ផានី	០២៩៤៧៧	ជំនួយការប្រេងឥន្ធនៈការិយាល័យទី៤
១៩-	វរសេនីយ៍ត្រី	សិក	ស៊ុន	១៤៥៧០៥	ជំនួយការបរិក្ខាការិយាល័យទី៤ យោធភូមិភាគទី៤
២០-	វរសេនីយ៍ត្រី	ម៉ី	មួរ	០១៩០៥៥	មេបញ្ជាការវរស៊ើបការណ៍ យោធភូមិភាគទី៤
២១-	វរសេនីយ៍ត្រី	ប្រាក់	សាវ៉ាន់	០៤១៦០៦	មេបញ្ជាការរងវរស៊ើបការណ៍ យោធភូមិភាគទី៤
២២-	វរសេនីយ៍ត្រី	អ៊ូ	ចាន់ណា	០៥០៤៧១	មេបញ្ជាការរងវរស៊ើបការណ៍ យោធភូមិភាគទី៤
២៣-	វរសេនីយ៍ត្រី	ខៀវ	ម៉ូច	០៤១៥៨៨	មេបញ្ជាការរងវរស៊ើបការណ៍ យោធភូមិភាគទី៤
២៤-	វរសេនីយ៍ត្រី	ឆេង	ធី	០៥០៤៧៣	មេបញ្ជាការរងវរស៊ើបការណ៍ យោធភូមិភាគទី៤
២៥-	វរសេនីយ៍ត្រី	លី	ដុល្លារដ្ឋ	០៥០៤៦១	សេនាធិការ វរស៊ើបការណ៍ យោធភូមិភាគទី៤
២៦-	វរសេនីយ៍ត្រី	ឆៃ	ហួន	០៥៩៨៧៧	មេគ១ស៊ើបការណ៍ យោធភូមិភាគទី៤
២៧-	វរសេនីយ៍ត្រី	យ៉ាន់	ឡុងឌី	០១៧៤៨៤	មេបញ្ជាការរង វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
២៨-	វរសេនីយ៍ត្រី	ឈាង	ញា	០៥០៥៣០	មេបញ្ជាការរង វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
២៩-	វរសេនីយ៍ត្រី	សួរ	សុន	០៥០៥១៦	សេនាធិការ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៣០-	អនុសេនីយ៍ឯក	ជ័យ	រុន	០៥០៤៥៩	ជំនួយការតំបន់អភិវឌ្ឍន៍ យោធភូមិភាគទី៤
៣១-	អនុសេនីយ៍ឯក	ជុរ	ពៅ	០២៧០៤៣	ជំនួយការផ្នែកសន្តិសុខ.ការិយាល័យទី១
៣២-	អនុសេនីយ៍ឯក	ស៊ិន	ស៊ីយឿន	០៥០៣៤៣	ជំនួយការលេខាធិការដ្ឋាន យោធភូមិភាគទី៤
៣៣-	អនុសេនីយ៍ឯក	គីម	សុភា	០៦៨០៣៥	ជំនួយការឯកទេសសុខាភិបាល យោធភូមិភាគទី៤
៣៤-	អនុសេនីយ៍ឯក	ខៀវ	សំអឿន	០៣៧៣៦៤	ជំនួយការអាវុធគ្រាប់ ការិយាល័យទី៤

៣៥-	អនុសេនីយ៍ឯក	វុត្ថ	ចិនឈឿន	០៥០៣៩១	ជំនួយការស្បៀង ការិយាល័យទី៤ យោធភូមិភាគទី៤
៣៦-	អនុសេនីយ៍ឯក	ស្វាយ	សាខុធ	០៣៤២៣៥	ជំនួយការដឹកជញ្ជូន ការិយាល័យទី៤ យោធភូមិភាគទី៤
៣៧-	អនុសេនីយ៍ឯក	ថន	ថាវី	០៥៩៨៤០	ជំនួយការជួសជុល ការិយាល័យទី៤ យោធភូមិភាគទី៤
៣៨-	អនុសេនីយ៍ឯក	ស្មិន	កើត	០៥០៥៥៩	ជំនួយការបុគ្គលិក វរសេនាធំ...
៣៩-	អនុសេនីយ៍ឯក	ញិប	នៅស៊ន់	០៥០៥០១	ជំនួយការហិរញ្ញវត្ថុ វរសេនាធំ...
៤០-	អនុសេនីយ៍ទោ	ម៉ូ	ចាន់ណា	០៤១៦១២	គ្រូពេទ្យមធ្យម មន្ទីរពេទ្យ យោធភូមិភាគទី៤
៤១-	អនុសេនីយ៍ទោ	អឿម	ឈឿម	០៤១៦១១	ជំនួយការឯកទេសសុខាភិបាល យោធភូមិភាគទី៤
៤២-	អនុសេនីយ៍ទោ	ប្រៀន	ប្រីយ	០៨៩០៤៤	ជំនួយការបញ្ជូនសារ គ.គាំទ្រ វរសេនាធំ...
៤៣-	អនុសេនីយ៍ទោ	ម៉ៃ	សាម៉េត	០៥០៥៦៥	មេគ គាំទ្រ វរសេនាធំ... យោធភូមិភាគទី៤
៤៤-	អនុសេនីយ៍ទោ	ស្ងួន	រ៉ែម	០៥០៥៧២	មេគ២ វរសេនាធំ... យោធភូមិភាគទី៤
៤៥-	អនុសេនីយ៍ទោ	សាម	ឡា	១០៣៧០៦	មេគលេខ១ វរសេនាធំ... យោធភូមិភាគទី៤
៤៦-	អនុសេនីយ៍ទោ	ពុធ	សុខេមរា	១០០៧៩៤	មេគ៣ វរសេនាធំ... យោធភូមិភាគទី៤
៤៧-	អនុសេនីយ៍ទោ	ម៉ៅ	តារី	១០០៧០៨	មេរងគ២ វរសេនាធំ... យោធភូមិភាគទី៤
៤៨-	អនុសេនីយ៍ទោ	ជា	ញ៉ិល	១៤៥៧៤៣	មេបញ្ជាការគ១ វរសេនាធំ... យោធភូមិភាគទី៤
៤៩-	អនុសេនីយ៍ទោ	គង់	សុភ័ក្រ	១៤៥៧៥០	មេរងគ២ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៥០-	អនុសេនីយ៍ទោ	ឈឿន	នឿន	០៥០៥២៩	មេបញ្ជាការរង វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៥១-	អនុសេនីយ៍ត្រី	កុយ	លីហ៊ួន	១៤៥៧០០	ជំនួយការឯកទេសវិស្វកម្ម យោធភូមិភាគទី៤
៥២-	អនុសេនីយ៍ត្រី	ម៉ូ	ចិនថា	២០២២៨៣	ជំនួយការការិយាល័យទី២ យោធភូមិភាគទី៤
៥៣-	អនុសេនីយ៍ត្រី	នឿន	សុផល	១៤៥៧៨៥	ជំនួយការផ្នែកសន្តិសុខ ការិយាល័យទី១
៥៤-	អនុសេនីយ៍ត្រី	ហែម	ចិត	០៥៩៩២១	មេរង គគាំទ្រវរសេនាធំ... យោធភូមិភាគទី៤
៥៥-	អនុសេនីយ៍ត្រី	ប៊ុច	អុល	១០១៥៧៤	មេខ១២,៧គគាំទ្រ វរសេនាធំ... យោធភូមិភាគទី៤
៥៦-	អនុសេនីយ៍ត្រី	ឈួន	ខឿម	០៥១៣៥១	មេខ.ត្បាល់.៨២.គគាំទ្រវរសេនាធំ...
៥៧-	អនុសេនីយ៍ត្រី	ថោង	មុន្នី	១០១៤៨២	រងខ ត្បាល់៨២ គាំទ្រ វរសេនាធំ...
៥៨-	អនុសេនីយ៍ត្រី	ស៊ុំ	ម៉ៅ	០៥៩៩១៧	មេរង គ គាំទ្រ វរសេនាធំ... យោធភូមិភាគទី៤
៥៩-	អនុសេនីយ៍ត្រី	គីម	ថាត	០៥៩៩១៤	មេ ខ គគាំទ្រ វរសេនាធំ... យោធភូមិភាគទី៤
៦០-	អនុសេនីយ៍ត្រី	ស៊ាប	ស៊ីម	០៦០២៥៩	មេខ២ គ២ វរសេនាធំ... យោធភូមិភាគទី៤

៦១-	អនុសេនីយ៍ត្រី	កែវ	ម៊ុនឈឿន	១០៥៨៦៨	មេគ១.វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៦២-	នាយចំណង់	ខេ	ឌិក	១០១៦០៣	មេក្រុម២.ខ២.គ២វរសេីបការណ៍ យោធភូមិភាគទី៤
៦៣-	នាយចំណង់	ចាប	តឿក	១០១៤៩៧	មេក្រុម២.គ២វរសេីបការណ៍ យោធភូមិភាគទី៤
៦៤-	នាយចំណង់	ម៉ុច	សុផល	០៧២១៧៤	ជំនួយការអាវុធគ្រាប់ វរសេនាតូចវិស្វកម្ម
៦៥-	នាយចំណង់	ឈឿន	ឈើយ	១៤៥៧០១	មេខ១.គ៣វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៦៦-	នាយចំណង់	ម៉ៅ	មើយ	០៥០៥២៥	មេខ២.គ២.វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៦៧-	ព្រិន្ទបាលឯក	កុល	ពិសី	១៥៨៩៤៧	ជំនួយការកុំព្យូទ័រ លេខធិការដ្ឋាន យោធភូមិភាគទី៤
៦៨-	ព្រិន្ទបាលឯក	ភិក	បូរិន	២០២៣២១	គិលានុបដ្ឋាកបឋម មន្ទីរពេទ្យ យោធភូមិភាគទី៤
៦៩-	ព្រិន្ទបាលឯក	ម៉ិល	ហាយ	១០៥៤៦៩	ជំនួយការវិស្វកម្ម គគាំទ្រសេីបការណ៍ យោធភូមិភាគទី៤
៧០-	ព្រិន្ទបាលឯក	ហ៊ៅ	ហឿយ	០៧២១៨៣	ជំនួយការវិស្វកម្ម គគាំទ្រសេីបការណ៍ លេខាធិការដ្ឋាន
៧១-	ព្រិន្ទបាលឯក	យឹម	ឃុយ	១០០៨៤៤	មេវងខ ការពារ វរសេីបការណ៍ យោធភូមិភាគទី៤
៧២-	ព្រិន្ទបាលឯក	ឡឿន	ដារ៉ា	១០១៥៥២	វង ខ DKZ គគាំទ្រវរសេីបការណ៍ យោធភូមិភាគទី៤
៧៣-	ព្រិន្ទបាលឯក	សោម	ឈួន	២១០៦៣០	មេក្រុម គគាំទ្រវរសេីបការណ៍ យោធភូមិភាគទី៤
៧៤-	ព្រិន្ទបាលឯក	ជិម	ចិន្តា	០៧៩០៨៩	ជំនួយការវិស្វកម្ម គគាំទ្រវរសេីបការណ៍ យោធភូមិភាគទី៤
៧៥-	ព្រិន្ទបាលឯក	គីង	តឿក	១០១៥៤៥	ជំនួយការបើកបរ វរសេីបការណ៍ យោធភូមិភាគទី៤
៧៦-	ព្រិន្ទបាលឯក	ម៉ុត	ភ្លួក	២០៥០៨២	វងក្រុម១.ខការពារ វរសេីបការណ៍ យោធភូមិភាគទី៤
៧៧-	ព្រិន្ទបាលឯក	ម៉ៅ	ម៉ាន់	១០១៦០៥	វងក្រុម២.ខ១.គ២ វរសេីបការណ៍ យោធភូមិភាគទី៤
៧៨-	ព្រិន្ទបាលឯក	ម៉ៅ	ឆេន	០៥១២៩២	វងក្រុម២.ខ៣.គ២ វរសេីបការណ៍ យោធភូមិភាគទី៤
៧៩-	ព្រិន្ទបាលឯឥ	គោក	ម៉ាប់	២០១៩៧៥	វងក្រុម២.ខការពារ វរសេីបការណ៍ យោធភូមិភាគទី៤
៨០-	ព្រិន្ទបាលឯក	ឡឿម	ថ៉ាន់	១០៥៨៧២	យុទ្ធជន.ខការពារ វរសេីបការណ៍ យោធភូមិភាគទី៤
៨១-	ព្រិន្ទបាលឯក	ប៉ាវ	ឡា	១៤៧៦៩១	យុទ្ធជន ខការពារ វរសេីបការណ៍ យោធភូមិភាគទី៤
៨២-	ព្រិន្ទបាលឯក	ស៊ា	សួយ	០៨០២៧៤	មេក្រុម២.ខ១គាំទ្រ វរសេីបការណ៍ យោធភូមិភាគទី៤
៨៣-	ព្រិន្ទបាលឯក	ឡឿ	ដួល	០៥១២៩៥	មេក្រុម៣.ខ១.គ១ វរសេីបការណ៍ យោធភូមិភាគទី៤
៨៤-	ព្រិន្ទបាលឯក	សាត	អន	០៥១២២៣	មេក្រុម១.ខ១.គ១ វរសេីបការណ៍ យោធភូមិភាគទី៤
៨៥-	ព្រិន្ទបាលឯក	ទេព	ប៊ូរ៉ា	៨០០៩៩៦	ពេទ្យគ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៨៦-	ព្រិន្ទបាលឯក	ទូច	ធីណា	១០១១៤៦	វងពួក៣ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤

៨៧-	ព្រិន្ទបាលឯក	ហ្វូន	សុខិម	១០៤៦១៩	មេខ២ .គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៨៨-	ព្រិន្ទបាលឯក	ស្វាយ	យ៉ាន	០៦០២៥៨	មេខ២ .គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៨៩-	ព្រិន្ទបាលឯក	យ៉ាន់	សុភាព	០៧២៣២៣	មេគ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩០-	ព្រិន្ទបាលឯក	យ៉ាន់	យួន	០៥៩៩០៦	មេរង .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩១-	ព្រិន្ទបាលឯក	ខាត់	ខុន	២១៦៨៩១	មេខ២ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩២-	ព្រិន្ទបាលឯក	យឹម	ណាត	១០១២១១	មេខ២ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៣-	ព្រិន្ទបាលឯក	ម៉ៅ	ឃុន	១៤៥៧៥៣	មេក្រុម១ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៤-	ព្រិន្ទបាលឯក	នឹម	ឧត្តម	០៧២១១៧	បើកបរ គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៥-	ព្រិន្ទបាលឯក	ហ៊ុត	ស៊ីញ	១៤៥៦៩៣	រងខ១ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៦-	ព្រិន្ទបាលឯក	យុន	ឆា	០៨៩០៩២	រងពួក ២គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៧-	ព្រិន្ទបាលឯក	សឹម	តី	០៦០២៥១	មេក្រុម៣ .គ២ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៨-	ព្រិន្ទបាលឯក	ណាត់	ណាល់	០៧១៨៥៥	រងពួក៣ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
៩៩-	ព្រិន្ទបាលឯក	មឿន	ម៉េត	១០១១២៩	មេក្រុម២ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០០-	ព្រិន្ទបាលឯក	ឆេន	ថុន	១០១២១៧	មេក្រុម២ .គ២ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០១-	ព្រិន្ទបាលឯក	ឆៅ	អឿល	១០១១៩១	មេក្រុម៣ .គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០២-	ព្រិន្ទបាលឯក	ហៃល	ទីល	០៧៩៦៥៨	មេក្រុម១ ខ១.គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៣-	ព្រិន្ទបាលឯក	ហុង	ហ៊ួរ	២១៦៦៣៤	រងពួក២ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៤-	ព្រិន្ទបាលឯក	ឈឿន	ម៊ុនធឿន	១០៥១២២	មេក្រុម៣ .គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៥-	ព្រិន្ទបាលឯក	ម៉ឺន	ម៊ុនធឿន	១៤៥៦៨៤	រងក្រុម២ .គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៦-	ព្រិន្ទបាលឯក	ម៉យ	ពឿន	១៤៥៦៩៩	ជំនួយការបញ្ជូនសារ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៧-	ព្រិន្ទបាលឯក	រិន	រ៉ាន់	១៤៥៦៩៧	មេរងក្រុម១ .ខ១ គ៣ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៨-	ព្រិន្ទបាលឯក	សាន	ផានិត	២១៧៧៣៣	មេរងក្រុម២ ខ២ .គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១០៩-	ព្រិន្ទបាលឯក	ឡាក់	មាឌ	១៤៦៩១១	មេក្រុម២ .គ២ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១១០-	ព្រិន្ទបាលឯក	ឌិប	ធឿម	២២០៧១៨	មេរងក្រុម៣ ខ១.គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១១១-	ព្រិន្ទបាលឯក	យឿន	ឆក	១០៥៤៤១	មេពួក២ .គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១១២-	ព្រិន្ទបាលឯក	ឈាង	សៅ	១០១២០៦	យុទ្ធជន វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤

១១៣-	ព្រិន្ទបាលឯក	**ឃឿន**	**សាក់**	១០១៨៦៦	មេក្រុម១ ឧ១.គ១ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១១៤-	ព្រិន្ទបាលឯក	**យ៉ាន**	**ភក្តី**	១៤៦៨១២	ជំនួយការ បញ្ជូនសារ វរសេនាតូចវិស្វកម្ម យោធភូមិភាគទី៤
១១៥-	ព្រិន្ទបាលទោ	**ទៀន**	**ខុធ**	១៤៣៤៨៥	ជំនួយការបើកបរ មន្ទីរពេទ្យ យោធភូមិភាគទី៤
១១៦-	ព្រិន្ទបាលទោ	**តិក**	**ម៉ុនលឿន**	២០១៩៨៦	ពេទ្យបឋម មន្ទីរពេទ្យ យោធភូមិភាគទី៤
១១៧-	ព្រិន្ទបាលទោ	**សឿម**	**សយ**	០៥០៨៦៥	ពេទ្យបឋម មន្ទីរពេទ្យ យោធភូមិភាគទី៤
១១៨-	ព្រិន្ទបាលទោ	**យ៉ន**	**ហួច**	២២៣៦៩០	ពេទ្យបឋម មន្ទីរពេទ្យ យោធភូមិភាគទី៤
១១៩-	ពលបាលទោ	**ណាក់**	**ចាន់នី**	២៣៥៦៩៥	ជំនួយការបើកបរ មន្ទីរពេទ្យ យោធភូមិភាគទី៤

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ អនក្រ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការចម្រុះស៊ើបអង្កេត
ករណីស្លាប់ឈ្មោះ ឈុត វុទ្ធី និងឈ្មោះ អ៊ិន រតនា
កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមការចាំបាច់

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការចម្រុះស៊ើបអង្កេតករណីស្លាប់ឈ្មោះ ឈុត វុទ្ធី និងឈ្មោះ អ៊ិន រតនា កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង ដែលមានសមាសភាពដូចខាងក្រោម ៖

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ក់ ជីតូ** ប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ទោ **ស៊ិន សុផាន្នី** មេបញ្ជាការរង និងជាស្នងការនៃស្នងការដ្ឋាន ស្រាវជ្រាវ និងយុត្តិធម៌ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន

៣-ឯកឧត្តម **ទិត សុធា** អនុប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- លោក **គឹម សន្តិភាព** អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងយុត្តិធម៌ សមាជិក

៥- លោក **សោម សាធាន** អនុប្រធាននាយកដ្ឋាន ទទួលពាក្យបណ្តឹង និងអង្កេត ស្រាវជ្រាវ នៃ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

ប្រការ ២ : គណៈកម្មការចម្រុះមានភារកិច្ច ដូចតទៅ ៖

- ដឹកនាំស៊ើបអង្កេតករណីស្លាប់ឈ្មោះ ឈុត វុទ្ធី និងឈ្មោះ អ៊ិន រតនា កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ នៅក្នុងភូមិសាស្ត្រ ស្រុកមណ្ឌលសីមា ខេត្តកោះកុង
- ស្រាវជ្រាវរកមុខសញ្ញាដែលមានការពាក់ព័ន្ធក្នុងករណីសម្លាប់
- ស្រាវជ្រាវរកភស្តុតាង (សាក្សី និង វត្ថុតាង) ក្នុងករណីសម្លាប់
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដែនដី ស្ថាប័នច្បាប់ និងស្ថាប័នដែលមានការពាក់ព័ន្ធ អនុវត្តច្បាប់ដោយម៉ឺងម៉ាត់បំផុតចំពោះមុខសញ្ញាប្រព្រឹត្តបទល្មើស ដែលមានការពាក់ព័ន្ធក្នុង ករណីសម្លាប់នេះ
- ផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតប្រកបដោយភាពយុត្តិធម៌ ត្រូវធ្វើរបាយការណ៍ និង ការសន្និដ្ឋានឲ្យបានច្បាស់លាស់ករណីសម្លាប់នេះ រាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការចម្រុះនេះអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីជួយបំពេញការងារខាងលើ និង មានសិទ្ធិបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ ។

ប្រការ ៤ : គណៈកម្មការចម្រុះនេះមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងករណី ពាក់ព័ន្ធខាងលើ ។

ប្រការ ៥ : ទីតាំងបំពេញការងាររបស់គណៈកម្មការចម្រុះ អាស្រ័យលើប្រធានគណៈកម្មការជាអ្នកសម្រេច ។

ប្រការ ៦ : អនុប្រធាន និងសមាជិកគណៈកម្មការចម្រុះ ត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធាន គណៈកម្មការ ។

ប្រការ ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្តពាក់ព័ន្ធ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសមាសភាពដូចមានចែងក្នុងប្រការ ១ មានភារកិច្ច អនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២

ទីស្តីការគណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សសរ

សេចក្តីសម្រេច

ស្តីពី

ការប្រគល់ភារកិច្ចជូនស្ថាប័នរដ្ឋ
ដើម្បីយកឯកសាររបស់អ្នកជួលជាវសេវាទូរគមនាគមន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

